មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

# បទរំលោភសិទ្ធិមនុស្សនៅកម្ពុជា

## សំរាប់គំរោងប្រព័ន្ធចងក្រងទិន្នន័យ និងសេវាពត៌មានសាធារណៈ ស្តីអំពីការរំលោភសិទ្ធិមនុស្សនៅកម្ពុជា

ភ្នំពេញឆ្នាំ២០០៩

# បទរំលោភសិទ្ធិមនុស្សទូទៅនៅកម្ពុជា

*ការរៀបចំនេះធ្វើឡើងក្នុងគោលបំណងឲ្យស្ថាប័នដែលធ្វើការឃ្លាំមើល ស៊ើបអង្កេត និងតស៊ូមតិក្នុងករណីរំលោភសិទ្ធិមនុស្សអាចយល់ជារួមអំពីការងាររបស់ស្ថាប័នពាក់ព័ន្ធទាំងអស់។ លើសពីនេះ ការរៀបចំនេះអាចជាប្រយោជន៍សំរាប់ការជជែកពិភាក្សាអំពីការឲ្យនិយមន័យទៅលើប្រភេទរំលោភនីមួយៗដើម្បីធ្វើយ៉ាងណាឲ្យការចងក្រងករណីរំលោភសិទ្ធិមនុស្សកាន់តែមានលក្ខណៈស្របគ្នាជាងពេលបច្ចុប្បន្ន។*

## ការរំលោភសិទ្ធិមនុស្សជាអ្វី?

រហូតមកមានការជជែកគ្នាច្រើនអំពីអ្វីជាធាតុសំខាន់នៃការរំលោភសិទ្ធិមនុស្ស។ ពីមុនមកដោយយល់ឃើញអំពីកតព្វកិច្ចរបស់រដ្ឋចំពោះពលរដ្ឋរបស់ខ្លួន ការរំលោភសិទ្ធិមនុស្សត្រូវទទួលខុសត្រូវដោយរដ្ឋតែមួយគត់។ នៅក្នុងសន្និសិទពិភពលោកក្នុងទីក្រុងវីយ៉ែនកាលពីឆ្នាំ១៩៩៣ គេបានពង្រីកការយល់ឃើញលើបញ្ហាសិទ្ធិមនុស្សនិងការរំលោភសិទ្ធិមនុស្ស។ ការអះអាងថាសិទ្ធិមនុស្សរួមមានសិទ្ធិពលរដ្ឋ វប្បធម៌ សេដ្ឋកិច្ច នយោបាយ និងសង្គមដែលមិនអាចកាត់ផ្តាច់ចេញពីគ្នាបាននិងមានទំនាក់ទំនងគ្នាទៅវិញទៅមកក៏បានកំណត់ថាក្រៅពីភាគីរដ្ឋ ភាគីឯកជនផ្សេងទៀតក៏ត្រូវមានការទទួលខុសត្រូវដែរ។ នៅឆ្នាំ១៩៩៧ អ្នកតស៊ូមតិសំរាប់សិទ្ធិមនុស្សបានបញ្ជាក់អំពីការទទួលខុសត្រូវរបស់ភាគីឯកជននេះថែមទៀត និងបានកំណត់ជាមគ្គុទេស្ទក៏មួយផងដែរថា ការរំលោភសិទ្ធិមនុស្សកើតឡើងតាមរយៈ**អំពើផ្ទាល់របស់រដ្ឋ ឬភាគីដែលទទួលអំណាចគ្រប់គ្រាន់ពីរដ្ឋ** ឬតាមរយៈ**ការព្រងើយកន្តើយរបស់រដ្ឋ**។

## ប្រភេទនៃការរំលោភសិទ្ធិមនុស្ស

ប្រភេទបទរំលោភសិទ្ធិមនុស្សខាងក្រោមនេះជាប្រភេទបទរំលោភដែលតាមដានដោយអង្គការសិទ្ធិមនុស្សភាគច្រើននៅកម្ពុជាដែលផ្តោតការយកចិត្តទុកដាក់ខាងសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។ ការប្រើពាក្យពេចន៍មានការខុសគ្នាខ្លះ ប៉ុន្តែក្នុងករណីភាគច្រើនការឲ្យនិយមន័យផ្លូវច្បាប់មានលក្ខណៈស្របគ្នាតែមួយ ឬខុសគ្នាតិចតួចប៉ុណ្ណោះ។ ខាងក្រោមនេះជាប្រភេទករណីខុសៗគ្នាដែលគេតាមដានស៊ើបអង្កេត និងនិយមន័យនៃប្រភេទនីមួយៗ។

### ប៉ុងប៉ងធ្វើឃាត

ករណីនេះរួមមានរាល់សកម្មភាពឬពាក្យសំដី និងកាយវិការផ្សេងទៀតដែលធ្វើឲ្យបុគ្គលរងគ្រោះមានការភ័យខ្លាចថាមានគេប៉ុនប៉ងសំលាប់ខ្លួន។

ធាតុសំខាន់ៗត្រូវពិនិត្យមើលៈ
ជនរងគ្រោះជាជនសង្ស័យប្រព្រឹត្តិបទល្មើស ឬជនធម្មតា
មន្រ្តីមានសមត្ថកិច្ចជាអ្នកប្រព្រឹត្តិ
ជនរងគ្រោះត្រូវគេចាប់ខ្លួន ឬមិនចាប់ខ្លួន
មាត្រា៣១ ច្បាប់អ៊ុនតាក់

### ឃាតកម្ម (រួមមានប្រភេទតូចៗមួយចំនួនដូចខាងក្រោម)

#### ការប្រហារជីវិតក្រៅប្រព័ន្ធតុលាការ[1]

រាល់អំពើឃាតកម្មទាំងឡាយណាដែលកើតឡើងដោយកងកំលាំងមានសមត្ថកិច្ច ដែលធ្វើឡើងក្រៅនិតិវិធីច្បាប់គឺជាការប្រហារជីវិតក្រៅច្បាប់។ ការសំលាប់ដោយហ្វូងមហាជនក៏រាប់បញ្ចូលក្នុងនេះដែរ។

[1] អង្គការអាដហុកធ្វើការលើករណីរំលោភមួយដែលគេឲ្យឈ្មោះថា "ការប្រហារជីវិតក្រៅច្បាប់" ដែលសំដៅលើរាល់ឃាតកម្មទាំងឡាយណាដែលធ្វើឡើងដោយកងកំលាំងប្រដាប់អាវុធឬអ្នកអនុវត្តិច្បាប់ក្នុងបំណងណាមួយនិងឃាតកម្មដែលធ្វើឡើងដោយហ្វូងមនុស្ស។

ធាតុសំខាន់ៗត្រូវពិនិត្យមើល៖
ជនរងគ្រោះជាជនសង្ស័យប្រព្រឹត្តិបទល្មើស ឬជនធម្មតា
មន្ត្រីមានសមត្ថកិច្ចជាអ្នកប្រព្រឹត្តិ
ជនរងគ្រោះត្រូវគេចាប់ខ្លួន ឬមិនចាប់ខ្លួន
មាត្រា៣១ ច្បាប់អ៊ិនតាក់

### អំពើមនុស្សឃាតដោយហេតុផលនយោបាយ[2]

ករណីនេះរាប់បញ្ចូលនូវការសំលាប់បុគ្គលដែលធ្វើសកម្មភាពនយោបាយក្នុងកំរិតណាមួយ ដែលត្រូវរងគ្រោះដោយការសំលាប់ពីបុគ្គលដទៃដោយសារបញ្ហានយោបាយ។

ធាតុសំខាន់ៗត្រូវពិនិត្យមើល៖
ជនរងគ្រោះជាមនុស្សមានសកម្មភាពនយោបាយ
ជនរងគ្រោះជាជនសង្ស័យប្រព្រឹត្តិបទល្មើស ឬជនធម្មតា
មន្ត្រីមានសមត្ថកិច្ច ឬអ្នកបំរើនយោបាយឲ្យបក្សមួយផ្សេងទៀតជាអ្នកប្រព្រឹត្តិ
ជនរងគ្រោះត្រូវគេចាប់ខ្លួន ឬមិនចាប់ខ្លួន
មាត្រា៣១ ច្បាប់អ៊ិនតាក់
ហេតុផលនយោបាយ

## ការវាយដំបង្ករបួសស្នាម[3]

រាល់ការធ្វើឲ្យមានរបួសស្នាមលើបុគ្គលណាពីសំណាក់ភ្នាក់ងាររដ្ឋាភិបាលដែលមានសមត្ថកិច្ចត្រូវចាត់ទុកជាការរំលោភសិទ្ធិមនុស្ស។

ធាតុសំខាន់ៗត្រូវពិនិត្យមើល៖
រដ្ឋធម្មនុញ្ញមាត្រា៣៨
អ្នកប្រព្រឹត្តិ៖ មន្ត្រីមានសមត្ថកិច្ចប្រើប្រាស់តួនាទី
ជនរងគ្រោះ៖ ពលរដ្ឋ មន្ត្រីគ្មានអំណាច
បន្សល់ស្លាកស្នាម

## ការធ្វើទារុណ្ណកម្ម

រាល់អំពើដែលនាំឲ្យមានការឈឺចាប់ផ្នែកផ្លូវចិត្តផ្លូវកាយទោះក្នុងរយៈពេលណាក៏ដោយដែលធ្វើឡើងដោយភ្នាក់ងារមានសមត្ថកិច្ចក្នុងគោលបំណងបង្ខំទាញយកចំលើយ ឲ្យសារភាព ឬទទួលយកនូវការអះអាងផ្សេងទៀតត្រូវចាត់ទុកជាការធ្វើទារុញកម្ម។

ធាតុសំខាន់ៗត្រូវពិនិត្យមើល៖
ជនប្រព្រឹត្តិ៖ មន្ត្រីមានសមត្ថកិច្ចឬអ្នកស្និទ្ធិនឹងខ្លួន
ជនរងគ្រោះ៖ ពលរដ្ឋ អ្នកនយោបាយ
ការទាញយកការសារភាព ឬការចុះចូល ឬបញ្ឈប់សកម្មណាមួយ

---

[2] ការសំលាប់ដោយហេតុផលនយោបាយ ត្រូវបានសមាគមអាដហុកយកមកធ្វើការតាមដានដោយសំដៅលើរាល់ឃាតកម្មទាមងឡាយណាដែលធ្វើឡើងដោយជនណាម្នាក់ក្នុងបំណងបំបាក់ស្មារតីរបស់អ្នកគាំទ្រ សកម្មជនឬមន្ត្រីរបស់គណបក្សនយោបាយផ្សេងពីគណបក្សរបស់ខ្លួន។ អត្ថន័យនេះដូចគ្នានឹងអ្វីដែលមជ្ឈមណ្ឌលសិទ្ធិមនុស្សធ្វើការតាមដានដែរ។

[3] សមាគមអាដហុកឲ្យនិយមន័យបទរំលោភនេះថា″ជាអំពើទាំងឡាយណាដែលធ្វើឲ្យអ្នកដទៃមានរបួសក៏ប៉ុន្តែដោយអំពើនេះជាករណីព្រហ្មទណ្ឌទូទៅ សមាគមអាដហុកបានកំណត់យកជាអាណត្តិរបស់ខ្លួនតែក្នុងករណីបង្ករបួសស្នាមដែលកើតឡើងដោយទាហាន ប៉អ៊ឹម ប៉ូលីស កងជីវពលនិងអាជ្ញាធរមូលដ្ឋានដែលមានសមត្ថភាពឬក្រុមអ្នកមានអំណាចដែលស្និទ្ធនឹងអាជ្ញាធររដ្ឋាភិបាល″។

ការប្រើប្រាស់អំពើហឹង្សាបន្សល់ស្លាកស្នាម
ការធ្វើឲ្យមានប៉ះពាល់ដល់ផ្លូវកាយផ្លូវចិត្ត

## រំលោភ/ប៉ុនប៉ងរំលោភ

បើយោងតាមច្បាប់ព្រហ្មទណ្ឌអន្តរកាលមាត្រា៣៣ បទរំលោភសេពសន្ថវៈ ដែលនៅទីនេះយើងប្រើពាក្យ"ការចាប់រំលោភ"សំដៅលើគ្រប់អំពើបញ្ចូលអង្គជាតិដោយឃោរឃៅ ដោយបង្ខំ ឬដោយមិនដឹងខ្លួន។ លើសពីនេះទៀត រាល់ការប៉ុនប៉ងធ្វើដូច្នេះជាការប៉ុនប៉ងរំលោភ។

<u>ធាតុសំខាន់ៗត្រូវពិនិត្យមើលៈ</u>
ជនប្រព្រឹត្តិៈបុរស ធម្មតាឬអាជ្ញាធរ
ជនរងគ្រោះៈ ស្ត្រី កុមារី
ការសំរាតសំលៀកបំពាក់ចេញ
ការសង្កត់ពីលើ ឬអកប្បកិរិយាអៀបថើប
ការដាក់បញ្ចូលអង្គជាតិភេទ
ការចេញទឹកកាម
ការបន្សល់របួសស្នាមលើបុសនារី

## បៀតបៀនកេរ្តិ៍ខ្មាស់[4]

បៀតបៀនដល់កេរ្តិ៍ខ្មាស់ដែលធ្វើឡើងដោយភ្នាក់ងាររដ្ឋណាមួយឬភ្នាក់ងារមិនមែនរដ្ឋ ដែលមានអំណាចពិសេសលើជនណាម្នាក់ទៀតដែលមានភេទដូចគ្នាឬមិនដូចគ្នាដោយប្រព្រឹត្តិទៅលើជននោះតាមការស្ទាប អង្អែល ឬអំពើផ្សេងទៀតទាក់ទងនឹងរឿងភេទ ប៉ុន្តែពុំបានដល់ទីជម្រៅ។

<u>ធាតុសំខាន់ៗត្រូវពិនិត្យមើលៈ</u>
ជនរងគ្រោះៈ ប្រុស និងស្រី
ជនប្រព្រឹត្តិៈ មន្ត្រីរដ្ឋាភិបាល
ការប៉ះពាល់រាងកាយ ការប្រើពាក្យសំដីលែបខាយធ្វើឲ្យល្អក់កករដល់អារម្ភ
សៅហ្មងក្នុងចិត្ត

## ការចាប់ឃាត់និងឃុំឃាំងមនុស្សខុសច្បាប់

អំពើទាំងឡាយពាក់ព័ន្ធនឹងការឃាត់និងឃុំឃាំងមនុស្សដែលផ្ទុយនឹងមាត្រា១៣ និងមាត្រា៥៧នៃច្បាប់អ៊ុនតាក់ត្រូវចាត់ជាការឃាត់និងឃុំឃាំងខុសច្បាប់និងជាការរំលោភសិទ្ធិមនុស្ស។

<u>ធាតុសំខាន់ៗត្រូវពិនិត្យមើលៈ</u>
អត់មានដីការ
មិនមែនជាការប្រព្រឹត្តិបទល្មើសជាក់ស្តែង
អត់ប្រកាសពីដីការ

[4] អត្ថន័យនេះមានចែងក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាលមាត្រាទី៤២ ប៉ុន្តែសំរាប់ជាការរំលោភសិទ្ធិមនុស្សអ្នកប្រព្រឹត្តិគឺជាភ្នាក់ងាររបស់រដ្ឋឬអ្នកជិតដិតដែលទទួលអំណាចពីខ្លួន។ សំរាប់ជាបទល្មើសព្រហ្មទណ្ឌវិញ ការប្រព្រឹត្តិនេះអាចមានទោសជាប់គុកពី១ឆ្នាំទៅ៣ឆ្នាំ ហើយបើប្រព្រឹត្តិលើជនរងគ្រោះអាយុតិចជាង១៦ឆ្នាំរួមផ្សំទាំងអំពើហឹង្សាផងកំរិតទោសត្រូវទ្វេមួយជាពីរ។

## ការបាត់ខ្លួនដោយបង្ខំ

រាល់ការបាត់ខ្លួនបុគ្គលណាម្នាក់ក្រោយពីអាជ្ញាធរមានសមត្ថកិច្ចនាំទៅសាកសួរ យកទៅឃុំឃាំង ឬមានការប្រឈរមុខដាក់គ្នាក្នុងរឿងអ្វីមួយត្រូវចាត់ជាការរំលោភសិទ្ធិមនុស្ស។ ក្នុងករណីខ្លះអាចមានសាក្សីឃើញពីសកម្មភាពចុងក្រោយពាក់ព័ន្ធនឹងការបាត់ខ្លួន។

<u>ធាតុសំខាន់ត្រូវពិនិត្យមើល៖</u>

បាត់ខ្លួនដោយមិនមានមូលហេតុ
ធ្លាប់មានទំនាស់ជាមួយជនមានឥទ្ធិពលអំណាច
ត្រូវកងកំលាំងនាំខ្លួនទៅ
ត្រូវជាប់គុក

## ការជំរិតទារប្រាក់[5]

រាល់ការជំរិតទាប្រាក់ពីសំណាក់ភ្នាក់ងាររដ្ឋាភិបាលទោះតាមរយៈការចាប់ខ្លួន ការគំរាមគំហែងនិងមធ្យោបាយផ្សេងទៀតចាត់ជាការរំលោភសិទ្ធិមនុស្ស។

<u>ធាតុសំខាន់ៗត្រូវពិនិត្យមើល៖</u>

ចាប់ខ្លួនមិនមានមូលហេតុហើយសុំឲ្យបង់លុយសំរាប់ដោះលែង
ផ្អាកដំណើរហើយគំរាមយកលុយ
អាជ្ញាធរមានសមត្ថកិច្ចជាអ្នកជំរិត
ជំរិតទាលុយជាការដោះដូរនឹងការចោទប្រកាន់

## ការគំរាមកំហែង (រួមមានប្រភេទតូចៗមួយចំនួនដូចខាងក្រោម)[6]

### គំរាមកំហែងនយោបាយ

សកម្មភាពគំរាមកំហែងពលរដ្ឋណាម្នាក់ ឬអ្នកមានសកម្មភាពនយោបាយដើម្បីផលប្រយោជន៍នយោបាយមិនថាក្នុងគោលបំណងទទួលការគាំទ្រឬផ្លាស់ប្តូរនិន្នាការ ឬគោលបំណងនយោបាយផ្សេងទៀតពីសំណាក់អ្នកនយោបាយមានអំណាច ឬអាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់ជាករណីរំលោភសិទ្ធិមនុស្ស។

<u>ធាតុសំខាន់ៗត្រូវពិនិត្យមើល៖</u>

ជនរងគ្រោះ៖ អ្នកពាក់ព័ន្ធនឹងនយោបាយ
ជនប្រព្រឹត្តិ៖ ភ្នាក់ងាររដ្ឋាភិបាល មន្ត្រីបក្សដទៃ អ្នកស្និទ្ធិនឹងរដ្ឋាភិបាល
សកម្មភាពនយោបាយ
ឲ្យចុះចូល ចាកចេញ ឈប់ធ្វើសកម្មភាពនយោបាយ ឲ្យគាំទ្រខ្លួនបក្សខ្លួន
ការប្រើពាក្យដែលធ្វើឲ្យសៅហ្មង និងកាយវិកាធ្វើឲ្យប៉ះពាល់សុវត្ថភាពបុគ្គលក្រុម

---

[5] សមាគមអាដហុកប្រើពាក្យ“ការជំរិតទារប្រាក់”ដែលសំដៅលើការចាប់និងគំរាមកំហែងមនុស្សដើម្បីយកប្រាក់ដោយភ្នាក់ងាររដ្ឋាភិបាលរួមមានយោធា ប៉េអ៊ឹម ប៉ូលីស និងអាជ្ញាធរមូលដ្ឋាន។ ករណីភាគច្រើនកើតនៅតាមស្ថានីយ៍ប៉ូលីស និងកងរាជអាវុធហត្ថនិងនៅតុលាការដែលអាចជាថ្នូរក្នុងការដោះលែងមនុស្សឬធ្វើការលើកលែងការចោទប្រកាន់។ ចំណែកអង្គការលីកាដូប្រើពាក្យ "ការចាប់ជំរិត”ដែលសំដៅលើ"ការនាំមនុស្សទៅកន្លែងណាមួយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ជនល្មើសដើម្បីប្រព្រឹត្តិនូវអំពើអ្វីមួយខុសច្បាប់(ឧ ជំរិតទារប្រាក់ ឬដើម្បីយកទៅជួញដូរ) ដោយវិធីបង្ខំ គំរាមកំហែង បោកប្រាស់ ឬលួងលោម ឬដោយវិធីណាមួយដោយមិនបង្ខំក្នុងខណៈដែលជននោះមិនយល់ព្រម”។

[6] សមាគមអាដហុកឲ្យនិយមន័យលើការគំរាមកំហែងនេះធំទូលាយបន្តិច។ បើតាមសមាគមនេះ ការគំរាមកំហែងសំដៅលើការប្រព្រឹត្តិរបស់មន្ត្រីមានសមត្ថកិច្ចជាពាក្យសំដីឬកាយវិការដើម្បីបំពេញកតព្វកិច្ចរបស់ខ្លួននិងផលប្រយោជន៍របស់ខ្លួន។ ការគំរាមកំហែងនេះអាចធ្វើឡើងដល់ប្រជាពលរដ្ឋសាមញ្ញ សកម្មជនគណបក្សនយោបាយ និងអ្នកការពារសិទ្ធិមនុស្សជាដើម។ ឧទាហរណ៍មួយចំនួនអាដហុកផ្តល់ឲ្យរួមមានការបំបែកក្បួនដង្ហែររបស់សមាគមអាដហុកនៅរតនគីរីកាលពីថ្ងៃ១៩វិច្ឆិកា២០០៨ ការបំបែកកូដកម្មកម្មកររោងចក្រហ្វូជូនហ្កាមិនថ្ងៃទី២៩ វិច្ឆិកា២០០៨ ការគំរាមរបស់អាជ្ញាធរមូលដ្ឋានយកលុយដល់អ្នកកាប់ឈើជាគ្រួសារខុសច្បាប់ ការគំរាមរបស់ក្រឡាបញ្ជីរកចាប់ឃុំបើមិនបង់លុយ និងការគំរាមសំលាប់ដល់សកម្មជនគណបក្សនយោបាយជាដើម។ ទំព័រ១៧ដល់២២។

### ការគំរាមកំហែង និងការធ្វើទុកបុកម្នេញ

រាល់ការគំរាមកំហែង និងបំភិតបំភ័យ សកម្មភាពឫសំដីកំណាច ការគំរាម ការឆាឆៅ ឬបំភិតបំភ័យដល់ជនណាម្នាក់ពីសំណាក់ភ្នាក់ងារមានសមត្ថកិច្ច និងភ្នាក់ងារពាក់ព័ន្ធដែលអាចជាការគ្រោះថ្នាក់ដល់សុវត្ថភាពរបស់បុគ្គលឬក្រុមនោះទោះក្នុងគោលបំណងណាក៏ដោយត្រូវចាត់ទុកជាការគំរាមកំហែងនិងធ្វើទុកបុកម្នេញ។

<u>ធាតុសំខាន់ត្រូវពិនិត្យមើលៈ</u>
ជនរងគ្រោះៈ ពលរដ្ឋ
ជនប្រព្រឹត្តិៈ មន្រ្តីមានសមត្ថកិច្ច
ប្រើពាក្យពេចន៍ឲ្យគេខ្លាច
ឲ្យផ្អាកសកម្មភាពអ្វីមួយ

## ការគំរាមកំហែងដល់អាយុជីវិត

រាល់ការគំរាមកំហែងដល់អាយុជីវិតពីសំណាក់ភ្នាក់ងារមានសមត្ថកិច្ចដល់បុគ្គលណាម្នាក់ត្រូវចាត់ទុកការបទរំលោភសិទ្ធិមនុស្ស។ ការគំរាមនេះអាចកើតចេញពីការសំដែងកាយវិការ ឬពាក្យសំដីដែលធ្វើឲ្យជនរងគ្រោះមានការភ័យខ្លាច ។

<u>ធាតុសំខាន់ៗដែលត្រូវពិនិត្យមើលៈ</u>
ប្រើពាក្យដកហូតជីវិត
ពាក្យសំដៅដល់ការសំលាប់
ប្រើកាយវិកាដែលធ្វើឲ្យមានការភ័យខ្លាចដល់ជីវិត

## ការរឹបអូសនិងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិខុសច្បាប់

ប្រភេទបទរំលោភនេះរាប់បញ្ចូលទាំងករណីរឹបអូសនិងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ពលរដ្ឋណាម្នាក់ដោយខុសច្បាប់ពីសំណាក់ភ្នាក់ងាររដ្ឋាភិបាលឬក្រុមមនុស្សដែលស្និទ្ធិនឹងភ្នាក់ងារនោះ ឬមានការគាំទ្រពីភ្នាក់ងាររដ្ឋាភិបាល ដោយមិនត្រូវតាមនិតិវិធីច្បាប់។

<u>ធាតុសំខាន់ៗត្រូវពិនិត្យមើលៈ</u>
ការដកហូតទ្រព្យសកម្មសិទ្ធិ
ការវាយដុតបំផ្លាញចោលទ្រព្យ
ការដកហូតទ្រព្យស្របច្បាប់របស់បុគ្គលដោយមិនតាមនិតិវិធីច្បាប់

## ករណីទំនាស់ដីធ្លី (រួមមានប្រភេទតូចៗមួយចំនួនដូចខាងក្រោម)

### ការវាទយកដី

ការរឹបអូសដីធ្លីដោយផ្ទុយនឹងច្បាប់ដោយការប្រើប្រាស់ឈ្មោះអាជ្ញាធរណាមួយ ការប្រើកំលាំងឬការប្រព្រឹត្តិដោយបន្លំ។

<u>ធាតុសំខាន់ៗត្រូវពិនិត្យមើលៈ</u>
អ្នកប្រព្រឹត្តិៈ ទាហាន អ្នកមាននិងអ្នកមានអំណាច មន្ត្រីមូលដ្ឋាន
ជនរងគ្រោះៈ ពលរដ្ឋរស់តំបន់នោះ
លិខិតស្តីពីកម្មសិទ្ធិ និងឯកសារផ្លូវច្បាប់ផ្សេងទៀត
ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ

## ជំលាសដោយបង្ខំ

សំដៅលើការបង្ខំឲ្យមនុស្សចេញពីលំនៅនិងដីរបស់ខ្លួនដោយមិនស្របនឹងឆន្ទៈរបស់គាត់ ដែលជាម្ចាស់កម្មសិទ្ធិលើផ្ទះនឹងដីស្របច្បាប់ ដោយមិនមានយន្តការគ្រប់គ្រាន់។

ធាតុសំខាន់ៗត្រូវពិនិត្យមើល៖
ជនប្រព្រឹត្តិ៖ មន្ត្រីមូលដ្ឋាន កំលាំងប្រដាប់អាវុធ តុលាការ
ជនរងគ្រោះ៖ ប្រជាជនរស់នៅទីនោះ
ការប្រើកំលាំង ការបង្កប្រួសស្នាម ការចាប់ចង ការចោទប្រកាន់
ការបិទរបង
នៅពេលយប់

## ការផ្លាស់ប្តូរដី

ជាការយល់ព្រមពីសំណាក់មន្ត្រីមានសមត្ថកិច្ចក្នុងការដោះដូរទីតាំងដីឬអាគារណាមួយដែលមានពលរដ្ឋរស់នៅនឹងទីតាំងមួយផ្សេងទៀត។ ការដោះដូរនេះតំរូវឲ្យប្រជាជនរើទៅរស់នៅទីតាំងថ្មីមួយដោយមិនមានការយល់ព្រមឬយន្តការដោះស្រាយគ្រប់គ្រាន់និងសមស្របតាមលក្ខណៈច្បាប់។ ក្នុងករណីនេះ ប្រជាជនទាំងនេះត្រូវប្រឈមមុខនឹងការជំលាសចេញដោយបង្ខំ។

ធាតុសំខាន់ៗត្រូវពិនិត្យមើល៖
អ្នកប្រព្រឹត្តិ៖ មន្ត្រីមានសមត្ថកិច្ច តុលាការ
ជនរងគ្រោះ៖ អ្នកតាំងទីលំនៅនៅទីតាំងនេះ
ភស្តុតាងផ្លូវច្បាប់ស្តីអំពីកម្មសិទ្ធិ
ផលប្រយោជន៍សាធារណៈ
សំណងសមរម្យ
យន្តការដោះស្រាយ

## សម្បទានសេដ្ឋកិច្ច

សម្បទានសេដ្ឋកិច្ចសំដៅលើការផ្តល់ដីឯកជនរបស់រដ្ឋតាមរយៈកិច្ចសន្យាសម្បាទានសេដ្ឋកិច្ចសំរាប់ប្រើប្រាស់ផ្នែកកសិកម្មនិងកសិឧស្សាហកម្ម។ ប្រសិនបើធ្វើឡើងសំរាប់ផលប្រយោជន៍សាធារណៈ និងប៉ះពាល់ប្រជាជនដែលជាម្ចាស់កម្មសិទ្ធិ ប្រជាជនត្រូវទទួលបាននូវសំណងសមរម្យ។ ប្រសិនបើពុំដូច្នោះទេ ប្រជាជនទាំងនោះអាចប្រឈមមុខនឹងការជំលាសដោយបង្ខំ។

ធាតុសំខាន់ៗត្រូវពិនិត្យមើល៖
អ្នកប្រព្រឹត្តិ៖ រដ្ឋ ក្រុមហ៊ុន មន្ត្រីថ្នាក់ក្រោម
ជនរងគ្រោះ៖ ពលរដ្ឋមូលដ្ឋាន
ឯកសារផ្តល់សម្បាទាន
ឯកសារកាន់កាប់ដីរបស់ពលរដ្ឋ និងតំលៃផ្លូវច្បាប់ផ្សេងទៀត
ពុំមានយន្តការគ្រប់គ្រាន់

## ការជួញដូរមនុស្ស[7] (រួមមានប្រភេទតូចៗមួយចំនួនដូចខាងក្រោម)

### ការជួញដូរពលកម្ម

សំដៅលើការទិញ ការលក់ ការជ្រើសរើស ការដឹកជញ្ជូន ការផ្លាស់ទី ការរក្សា ឬការទទួលមនុស្សដោយវិធីណាមួយដូចមានចែងខាងក្រោម៖ ការប្រើប្រាស់ឬការគំរាមកំហែងប្រើកំលាំង ការបង្ខិតបង្ខំតាមទំរង់ផ្សេងៗ ចាប់ជំរិត ក្លែងបន្លំ ឬបោកបញ្ឆោត ការរំលោភដោយអំណាច ឬការរំលោភលើភាពទន់ខ្សោយនៃជនរងគ្រោះ ការផ្តល់ឬការទទួលប្រាក់កាសឬផ្តល់ផលចំណេញអ្វីមួយដើម្បីអោយមានការយល់ព្រមពីជនណាម្នាក់ដែលមានអំណាចលើជនដទៃទៀតដូចជាឪពុក ម្តាយដែលមានអំណាចលើកូនក្នុងគោលបំណងធ្វើការកេងប្រវ័ញ្ចលើកំលាំងពលកម្ម។

### ការជួញដូរផ្លូវភេទ

សំដៅលើការទិញ ការលក់ ការជ្រើសរើស ការដឹកជញ្ជូន ការផ្លាស់ទី ការរក្សា ឬការទទួលមនុស្សដោយវិធីណាមួយដូចមានចែងខាងក្រោម៖ ការប្រើប្រាស់ឬការគំរាមកំហែងប្រើកំលាំង ការបង្ខិតបង្ខំតាមទំរង់ផ្សេងៗ ចាប់ជំរិត ក្លែងបន្លំ ឬបោកបញ្ឆោត ការរំលោភដោយអំណាច ឬការរំលោភលើភាពទន់ខ្សោយនៃជនរងគ្រោះ ការផ្តល់ឬការទទួលប្រាក់កាសឬផ្តល់ផលចំណេញអ្វីមួយដើម្បីអោយមានការយល់ព្រមពីជនណាម្នាក់ដែលមានអំណាចលើជនដទៃទៀតដូចជាឪពុក ម្តាយដែលមានអំណាចលើកូនក្នុងគោលបំណងយកទៅជួញដូរផ្លូវភេទ។

### ការយកកូនចិញ្ចឹម

សំដៅលើការទិញ ការលក់ ការជ្រើសរើស ការដឹកជញ្ជូន ការផ្លាស់ទី ការរក្សា ឬការទទួលមនុស្សដោយវិធីណាមួយដូចមានចែងខាងក្រោម៖ ការប្រើប្រាស់ឬការគំរាមកំហែងប្រើកំលាំង ការបង្ខិតបង្ខំតាមទំរង់ផ្សេងៗ ចាប់ជំរិត ក្លែងបន្លំ ឬបោកបញ្ឆោត ការរំលោភដោយអំណាច ឬការរំលោភលើភាពទន់ខ្សោយនៃជនរងគ្រោះ ការផ្តល់ឬការទទួលប្រាក់កាសឬផ្តល់ផលចំណេញអ្វីមួយដើម្បីអោយមានការយល់ព្រមពីជនណាម្នាក់ដែលមានអំណាចលើជនដទៃទៀតដូចជាឪពុក ម្តាយដែលមានអំណាចលើកូនក្នុងគោលបំណងយកទៅចិញ្ចឹមខុសច្បាប់។

## ការរំលោភសិទ្ធិសេរីភាពបញ្ចេញមតិ (រួមមានប្រភេទតូចៗមួយចំនួនដូចខាងក្រោម)

### ការប្រើប្រាស់បទបរិហាកេរ្តិ៍ ផ្សាយពត៌មានមិនពិត និងញុះញង់ខុស[8]

តាមច្បាប់កម្ពុជាបទបរិហាកេរ្តិ៍សំដៅលើការពោលអះអាងឬទំលាក់កំហុសដោយអសុច្ចចិត្តដែលធ្វើឲ្យសៅហ្មងដល់ជននោះ ចំណែកការផ្សាយពត៌មានមិនពិតសំដៅលើការចែកឬបោះពុម្ពផ្សាយនូវពត៌មានដែលប្រាកចាកអំពីការពិតសំដៅធ្វើឲ្យខូចសណ្តាប់ធ្នាប់សាធារណៈឬគំរាមដល់សន្តិសុខជាតិសុទ្ធតែជាបទល្មើសព្រហ្មទណ្ឌ។ ការញុះញង់ជាសកម្មភាពដែលនាំឲ្យមានការប្រព្រឹត្តិបទល្មើស ការស្អប់ឬរើសអើងពូជសាសន៍សុទ្ធតែចាត់ទុកជាបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌខ្មែរ។ <u>រាល់ការបកស្រាយច្បាប់ប្រាសចាកអំពីខ្លឹមសារដែលមានចែងក្នុងច្បាប់ព្រហ្មទណ្ឌមាត្រា៥៩ដល់៦៣ ត្រូវចាត់ទុកជាការគំរាមដល់អ្នកបញ្ចេញមតិ។</u>

ធាតុសំខាន់ត្រូវពិនិត្យមើល៖
ជនប្រព្រឹត្តិជាអ្នកមានអំណាច តុលាការ
ជនរងគ្រោះជាអ្នកមិនមានអំណាច ពលរដ្ឋធម្មតា បក្សប្រឆាំង អ្នកសិទ្ធិមនុស្ស
ការបោះពុម្ពផ្សាយ
ការគំរាមប្តឹងពីបទទាំងនេះ

---

[7] សមាគមសិទ្ធិមនុស្សលីកាដូ។
[8] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។

ឆ្លើយតបហួសហេតុនឹងការបរិយាយរបស់ជនរងគ្រោះ
មាត្រាទី៥៩ ដល់៦៣ ច្បាប់អ៊ុនតាក់

## ការត្រួតពិនិត្យជាមុន

ការត្រួតពិនិត្យជាមុនសំដៅដល់សកម្មភាពទាំងឡាយណាដែលភាគីរដ្ឋាភិបាលធ្វើឡើងក្នុងបំណងឲ្យមានការកែប្រែនូវសេចក្ដីពិតដែលគេប្រុងនឹងបោះពុម្ព ឬផ្អាកការបោះពុម្ពទាំងស្រុងនូវផ្នែកនៃពត៌មានណាមួយដែលខ្លួនមិនមិនពេញចិត្ត។

ធាតុសំខាន់ត្រូវពិនិត្យមើល៖
ច្បាប់សារពត៌មានឆ្នាំ១៩៩៥
ជនប្រព្រឹត្តិជាអ្នកមានអំណាច រដ្ឋាភិបាល ក្រសួងពត៌មាន
ជនរងគ្រោះជាអ្នកសារពត៌មាន វិទ្យុ សារពត៌មានផ្សេងទៀត ពលរដ្ឋទូទៅ
មានការបោះពុម្ពផ្សាយ
ការគំរាម សកម្មភាពផ្សេងទៀតដើម្បីធ្វើយ៉ាងណាមិនឲ្យមានការចេញផ្សាយ
ការដកហូតឯកសារបោះពុម្ពផ្សាយ ការពន្យាពេលបោះពុម្ពចាក់ផ្សាយ ការបិទការផ្សាយ

## ការរាំងការនិយាយស្ដី

រាល់សកម្មភាពរំខានឬផ្អាកការនិយាយស្ដីនៅក្នុងពេលថ្លែងសន្ទរកថាឬក្នុងកិច្ចប្រជុំសាធារណៈណាមួយពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចក្នុងបំណងមិនអោយលើកឡើងអំពីបញ្ហាអ្វីមួយឬដោយអំណាងលើហេតុផលមិនសមរម្យត្រូវចាត់ទុកជាការរាំងការនិយាយស្ដី។

ធាតុសំខាន់ត្រូវពិនិត្យមើល៖
ជនរងគ្រោះ ជាអ្នកមិនមានអំណាច ជាជនជាតិភាគតិច
ជនប្រព្រឹត្តិជាអាជ្ញាធរ មន្ត្រីមានអំណាច ស្ថាប័នរដ្ឋ
ការផ្អាកការនិយាយ ថ្លែងសន្ទរកថា
ការបដិសេធមិនឲ្យនិយាយ
ការរើសអើងគណបក្ស ឬបក្សពួក
ការនិយាយអំពីបញ្ហាដែលរដ្ឋាភិបាលមិនសប្បាយចិត្ត

## ការបៀតបៀនអ្នកសារពត៌មាន

ករណីនេះរាប់បញ្ចូលទាំងការគំរាមកំហែង ការប្រើប្រាស់កំលាំង បង្ករបួសស្នាម ការដកហូតសំភារសំរាប់ការប្រកបវិជ្ជាជីវរបស់អ្នកសារពត៌មានពិសេសក្រោយពីមានការផ្សាយពត៌មាន ឬសកម្មកម្មភាពនៃការយកពត៌មាន។

ធាតុសំខាន់ត្រូវពិនិត្យមើល៖
អ្នកសារពត៌មានត្រូវគេគំរាមកំហែង ដកហូតកម្មសិទ្ធិលើកាមេរ៉ា ប្រដាប់ថតសំលេង
មន្ត្រីសាធារណៈអ្នកប្រព្រឹត្តិ
ប្រើអំពើហឹង្សា

## ការរិតត្បិតសិទ្ធិទទួលពត៌មាន

រាល់ការបដិសេធន៍នូវការចែកពត៌មានសាធារណៈដែលរដ្ឋាភិបាលកាន់កាប់ដោយមិនមានហេតុផលសមរម្យសុទ្ធិតែជាការរំលោភសិទ្ធិទទួលពត៌មានរបស់ពលរដ្ឋ និងត្រូវដាក់បញ្ចូលក្នុងផ្នែកនេះ។

ធាតុសំខាន់ៗត្រូវពិនិត្យមើលៈ
ជនប្រព្រឹត្តិជារដ្ឋាភិបាល សភា ស្ថាប័នរដ្ឋ មន្ត្រីមូលដ្ឋាន កំលាំងប្រដាប់អាវុធ
ជនរងគ្រោះ ជាអ្នកកាសែត មន្ត្រីអង្គការ ពលរដ្ឋទូទៅ
ការមិនផ្តល់ពត៌មានរដ្ឋាភិបាលមានដោយមិនមានហេតុផលត្រឹមត្រូវ
រាំងមិនឲ្យសួរពីសំណួរមួយចំនួន
មិនអនុញ្ញាតិឲ្យចែកផ្សាយពត៌មាន ខិតប័ណ្ណ សំបុត្រ ប៉ាណូ អំពីបញ្ហារសើប

## កង្វះឯករាជ្យភាពរបស់សារពត៌មាន

កង្វះឯករាជ្យភាពរបស់សារពត៌មានអាចបណ្តាលមកពីសារពត៌មានផ្ទាល់ដូច្នេះគេក៏ត្រូវទទួលខុសត្រូវចំពោះពលរដ្ឋផងដែរ។ ករណីមួយចំនួនទៀតបណ្តាលមកពីកង្វះក្របខ័ណ្ឌច្បាប់សំរាប់ឲ្យមានពត៌មានឯករាជ្យ។

ធាតុសំខាន់ត្រូវពិនិត្យមើល
ជនប្រព្រឹត្តិជាប្រព័ន្ធសារពត៌មាន និងរឺក្រសួងពត៌មាន
ជនរងគ្រោះជាពលរដ្ឋទូទៅ និងស្ថាប័នសារពត៌មាន
ការបដិសេធមិនឲ្យបើវិទ្យុនិងស្ថានីយ៍ដោយការរើសអើង
សារពត៌មានមិនឯករាជ្យ មិនចំណុះឲ្យបក្សកាន់អំណាច

## ការរំលោភសេរីភាពបញ្ចេញមតិដោយខាងផ្លូវច្បាប់

រាល់ឯកសារច្បាប់ទាំងឡាយណាដែលចែងឡើងផ្ទុយនឹងគោលការណ៍នៃសេរីភាពបញ្ចេញមតិ ត្រូវយកមកសិក្សាវិភាគនឹងចាត់ជាការរំលោភសិទ្ធិសេរីភាពបញ្ចេញមតិ។

ធាតុសំខាន់ត្រូវពិនិត្យមើលៈ
ការអនុវត្តច្បាប់ដែលរំលោភសេរីភាពបញ្ចេញមតិ
ការមិនអនុវត្តច្បាប់ដែលគាំទ្រសេរីភាពបញ្ចេញមតិ
ការលុបចោលច្បាប់ដែលគោលរពសេរីភាពបញ្ចេញតមិ
ការចេញសេចក្តីសំរេចផ្ទុយពីគោលការណ៍សេរីភាពបញ្ចេញមតិ

# ការរំលោភសិទ្ធិសេរីភាពការជួបប្រជុំ (រូមមានប្រភេទតូចៗមួយចំនួនដូចខាងក្រោម)[9]

## ការបិទការិយាល័យ

សកម្មភាពបិទការិយាល័យរបស់ក្រុមឬសមាគម សហជីពណាមួយដោយល្មើសនឹងនិតិវិធីផ្លូវច្បាប់ត្រូវចាត់ទុកជាការរំលោភសិទ្ធិជួបប្រជុំ និងបង្កើតសមាគម និងស្ថិតក្នុងប្រភេទនេះ។

ធាតុសំខាន់ត្រូវពិនិត្យមើលៈ
ការិយាល័យត្រូវបានបិទ
ហេតុផលមិនស្របច្បាប់
មិនធ្វើឡើងតាមយន្តការច្បាប់
ហេតុផលនយោបាយ និងផលប្រយោជន៍បុគ្គល
មន្ត្រីអាជ្ញាធរជាអ្នកប្រព្រឹត្តិ

[9] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។

## ការរារាំងក្រុមណាមួយមិនឲ្យបង្កើតជាក្រុម

ការរារាំងនេះអាចកើតឡើងពីការបកស្រាយរាល់លក្ខខ័ណ្ឌទាំងឡាយដែលមានចែងក្នុងច្បាប់ក្នុងបំណងមិនអនុញ្ញាតិឲ្យក្រុមណាមួយបង្កើតឡើងដោយស្របច្បាប់ ដោយសារការរើសអើងនយោបាយឬការរើសអើងផ្សេងទៀត ឬដោយមិនមានហេតុផលសមរម្យណាមួយ។

ធាតុសំខាន់ត្រូវពិនិត្យមើលៈ
ក្រុមមនុស្សណាមួយដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់
មន្ត្រីមានសមត្ថកិច្ចហាមឃាត់ដោយហេតុផលមិនសមរម្យ
តុលាការបដិសេធដំណើរការក្តី ឬកាត់លំអៀង
ហេតុផលនយោបាយ ឬផលប្រយោជន៍បុគ្គលក្រុម
អាចប៉ះពាល់ដល់ផលប្រយោជន៍សេដ្ឋកិច្ចនយោបាយ

## ការបដិសេធការជួបប្រជុំអហឹង្សា

ការបដិសេធការជួបប្រជុំអហឹង្សាកើតឡើងនៅពេលដែលក្រុមអង្គការសមាគមណាមួយរៀបចំការជួបប្រជុំដោយអហឹង្សានិងផ្តល់ពត៌មានទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ហើយអាជ្ញាធរបែជារកហេតុផលមិនសមរមមកធ្វើការបដិសេធ និងអាចគំរាមប្រើវិធានការផ្សេងៗប្រសិនបើអ្នកស្នើសុំនៅតែបន្តធ្វើ។

ធាតុសំខាន់មួយចំនួនត្រូវពិនិត្យមើលៈ
លិខិតជូនដំណឹង(ស្នើសុំ) ត្រូវបដិសេធ
អាជ្ញាធរមានសមត្ថកិច្ចផ្តល់ហេតុផលមិនសមរម្យ
ផលប្រយោជន៍របស់អ្នកគ្រោងចូលរួមត្រូវខាតបង់
អ្នកប្រព្រឹត្តិជាមន្ត្រីក្រសួងមានសមត្ថកិច្ច ឬជាតុលាការ

## ការរំខានដល់ការជួបប្រជុំតាមទីសាធារណៈ

ការរំខានទាំងឡាយដល់ការជួបប្រជុំតាមទីសាធារណៈរួមមានការបំបែក ការបង្ករបួសស្នាម ការបង្កើតឲ្យមានការធ្វើបាតុកម្មប្រឆាំង និងហេតុភេតុផ្សេងទៀតដែលនាំការរំខានដល់ការប្រព្រឹត្តិទៅនៃការជួបប្រជុំត្រូវចាត់ជាការរំលោភសិទ្ធិនៃការជួបប្រជុំ និងត្រូវចងក្រងឡើងដាក់ក្នុងប្រភេទបទរំលោភនេះ។

ធាតុសំខាន់ៗត្រូវពិនិត្យមើលៈ
ការបំបែកការជួបប្រជុំ
ការអនុញ្ញាតិឲ្យមានការជួបប្រជុំប្រឈមគ្នា
ការបង្កហេតុភេទផ្សេងទៀត
ការបង្កអំពើហឹង្សា
ការចោទប្រកាន់ផ្លូវច្បាប់ ការទំលាក់កំហុស

## ការរំលោភសេរីភាពជួបប្រជុំផ្នែកផ្លូវច្បាប់

រាល់ច្បាប់ទាំងឡាយណាដែលអនុវត្តនៅក្នុងប្រទេសតែផ្ទុយនឹងគោលការគោរពសិទ្ធិជួបប្រជុំអន្តរជាតិត្រូវចាត់ទុកជាការរំលោភសិទ្ធិសេរីភាពនេះនឹងត្រូវវិភាគចងក្រងនិងដាក់បញ្ចូលក្នុងប្រភេទនេះ។ លើសពីនេះទៀត រាល់ច្បាប់ផ្សេងទៀតដែលល្អគាំទ្រដល់សិទ្ធិនេះប៉ុន្តែត្រូវបានគេលុបចោលទៅវិញ ក្នុងត្រូវចងក្រងនៅទីនេះដែរ។

ធាតុសំខាន់ៗត្រូវពិនិត្យមើលៈ
ការប្រកាសឲ្យប្រើច្បាប់ឬសេចក្តីប្រកាសដែលរំលោភលើសេរីភាពជួបប្រជុំ

ការលុបចោលច្បាប់ដែលការពារសេរីភាពជួបប្រជុំ
ជនរងគ្រោះៈពលរដ្ឋទូទៅក្នុងប្រទេស

**ករណីរំលោភទាក់ទងនឹងការបោះឆ្នោត** (រួមមានប្រភេទតូចៗមួយចំនួនដូចខាងក្រោម)[10]

## មិនអនុញ្ញាតអោយចុះឈ្មោះ

សំដៅលើករណីដែលពលរដ្ឋដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ក្នុងការបោះឆ្នោតមិនត្រូវបានភ្នាក់ងារមានសមត្ថកិច្ចបដិសេធមិនចុះឈ្មោះឲ្យដោយហេតុផលផ្ទាល់ខ្លួនណាមួយក្រៅផ្លូវច្បាប់។

## មិនអនុញ្ញាតិឲ្យបោះឆ្នោត

សំដៅលើករណីដែលពលរដ្ឋដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ក្នុងការបោះឆ្នោតមិនត្រូវបានភ្នាក់ងារមានសមត្ថកិច្ចបដិសេធឲ្យបោះឆ្នោតដោយហេតុផលផ្ទាល់ខ្លួនណាមួយក្រៅផ្លូវច្បាប់។

## ការប្រមូលប័ណ្ណបោះឆ្នោត

ជាការប្រមូលប័ណ្ណបោះឆ្នោតពីសំណាក់អាជ្ញាធរ ឬអ្នកស្និទ្ធិនឹងខ្លួននៅមុនថ្ងៃបោះឆ្នោតដោយហេតុផលពុំស្របច្បាប់ ហើយប្រហែលជាក្នុងបំណងធ្វើឲ្យអាក់ខានបោះឆ្នោត។

## ការទិញសន្លឹកឆ្នោត

សំដៅលើសកម្មភាពរបស់មន្ត្រីមានសមត្ថកិច្ចឬគណបក្សនយោបាយក្នុងការប្រើប្រាស់សំភារៈ ឬលាភសាក្ករផ្សេងទៀតដើម្បីជាការដោះដូរនឹងការគាំទ្រនិងបោះឆ្នោតជូនគណបក្សណាមួយដោយផ្ទុយពីឆន្ទះរបស់ខ្លួន។

## ការបង្ខំឲ្យស្បថ

សំដៅលើការបង្ខំរបស់អាជ្ញាធរឬមន្ត្រីគណបក្សឲ្យបុគ្គលណាម្នាក់ដែលជាសមាជិករបស់ខ្លួនក្តីឬអ្នកគាំទ្រក្តីស្បថថានឹងឲ្យបោះឆ្នោតឲ្យគណបក្សណាមួយទោះតាមរយៈការផឹកទឹកសម្បថ មន្តអាគម និងវិធីផ្សេងទៀតក៏ដោយ។

## ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋដើម្បីផលប្រយោជន៍គណបក្ស

ប្រភេទបទរំលោភនេះសំដៅលើការប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈ ទ្រព្យសម្បត្តិរដ្ឋ ឬថវិការដ្ឋដើម្បីប្រយោជន៍គណបក្សក្នុងនោះមានដូចជាការប្រើប្រាស់រថយន្តរដ្ឋធ្វើការឃោសនាគណបក្សនយោបាយ។

## ការរំខានក្នុងការលើកផ្លាកគណបក្ស

ការរំខានក្នុងការលើកផ្លាកគណបក្ស ការបំផ្លិចបំផ្លាញ ឬការធ្វើឲ្យខូចខាតតាមមធ្យោបាយផ្សេងទៀតដោយពុំមានធ្វើឡើងតាមច្បាប់។

## ការផ្សាយពត៌មានមិនមានតុល្យភាពមុនពេលបោះឆ្នោត

ធាតុសំខាន់ត្រូវពិនិត្យមើល
ការចែកម៉ោងផ្សាយមិនមានតុល្យភាព
គណបក្សនយោបាយ
ការរើសអើងការជួល

[10] សមាគមសិទ្ធិមនុស្សលីកាដូ។

ការរើសអើងម៉ោងផ្សាយ

## អាជ្ញាធរមិនអនុវត្តតួនាទី

អាជ្ញាធរបដិសេធ ឬមិនយកចិត្តទុកដាក់ក្នុងការអនុវត្តតួនាទីរបស់ខ្លួនដែលប៉ះពាល់ដល់ផលប្រយោជន៍ជនរងគ្រោះ។ ការប៉ះពាល់ផលប្រយោជន៍នេះអាចស្តែងឡើងតាមរយៈការរើសអើង ការព្រងើយកន្តើយ និងការខកខានផ្សេងទៀត ដែលបណ្តាលមកពីហេតុផលផ្សេងៗផ្ទុយអំពីច្បាប់។

## ការរើសអើងជនជាតិខ្មែរកម្ពុជាក្រោម

ការរើសអើងជនជាតិខ្មែរកម្ពុជាក្រោមពីសំណាក់អាជ្ញាធរកម្ពុជាអាចមានលេខចេញក្នុងរូបរាងច្រើនដូចជាការប្រកាន់ មិនផ្តល់ការអនុញ្ញាតិអោយចូលសាលារៀន ឡើងឋានៈ ឬផលប្រយោជន៍ផ្សេងទៀតដែលពលរដ្ឋកម្ពុជាទូទៅទទួលបាន។ រាល់សកម្មភាពរើសអើងទាំងនេះត្រូវចាត់ជាការរំលោភលើជនជាតិខ្មែរកម្ពុជាក្រោម។

## ករណីផ្សេងទៀត

រាល់ករណីដែលកើតឡើងហើយត្រូវបានគិតថាជាករណីរំលោភសិទ្ធិមនុស្សដែលមិនមានចូលនឹងការរំលោភណាមួយខាងលើអាចដាក់បញ្ចូលក្នុងផ្នែក״ករណីដទៃទៀត״បាន។ (ប្រសិនជាករណីកើតឡើងដាក់បញ្ចូលក្នុងប្រភេទនេះកើតឡើងមានចរិកលក្ខណៈដដែលៗអ្នកចងក្រងឯកសារអាចពិចារណាបង្កើតជាប្រភេទបទរំលោភថ្មីបាន)។

<u>**ឯកសារយោង**</u>


រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា

ច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល

អនត្តស៊ើបអង្កេតរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

អាដហុក ការស៊ើបអង្កេត

លីកាដូ ប្រភេទការរំលោភសិទ្ធិមនុស្សរបស់លីកាដូ

ការស៊ើបអង្កេតសិទ្ធិមនុស្ស